# អ្នកមានសិទ្ធិទទួលបានការ **"ប៉ាន់ប្រមាណថ្លៃថែទាំសុខភាពប្រកបដោយភាពជាក់លាក់"** ដែលបង្ហាញថាតើថ្លៃថែទាំសុខភាពរបស់អ្នកអាចអស់ប៉ុន្មាន

ក្រោមច្បាប់នេះ អ្នកផ្ដល់សេវាថែទាំសុខភាព ត្រូវប្រាប់អ្នកជំងឺដែលមិនបានទិញ ឬ មិនប្រើសេវាធានារ៉ាប់រងសុខភាព អំពីការប៉ាន់ប្រមាណថ្លៃឧបករណ៍/បរិក្ខារពេទ្យ និងសេវាវេជ្ជសាស្ត្រ ។

» អ្នកមានសិទ្ធិទទួលបានការប៉ាន់ប្រមាណថ្លៃថែទាំសុខភាពប្រកបដោយភាពជាក់លាក់ អំពីថ្លៃចំណាយសរុបដែលអ្នកជំងឺត្រូវបង់ លើឧបករណ៍/បរិក្ខារពេទ្យ និងសេវាថែទាំវេជ្ជសាស្ត្រដែលមិនមែនសម្រាប់ប្រើក្នុងស្ថានភាពអាសន្ន ។ ក្នុងនេះ គឺរួមបញ្ចូលនូវថ្លៃចំណាយដែលពាក់ព័ន្ធ ដូចជាថ្លៃធ្វើតេស្ត ថ្លៃថ្នាំដែលមានវេជ្ជបញ្ជា ថ្លៃឧបករណ៍/បរិក្ខារពេទ្យ និងថ្លៃសេវាមន្ទីរពេទ្យ ។

» ត្រូវប្រាកដថា អ្នកផ្ដល់សេវាថែទាំវេជ្ជសាស្ត្ររបស់អ្នក បានប្រាប់អ្នកនូវ ការប៉ាន់ប្រមាណថ្លៃថែទាំសុខភាពប្រកបដោយភាពជាក់លាក់ ជាលាយល័ក្ខណ៍អក្សរ

យ៉ាងហោចណាស់ចំនួនមួយថ្ងៃនៃថ្ងៃធ្វើការ មុនអ្នកទទួលបានសេវា ឬឧបករណ៍/បរិក្ខារពេទ្យ នោះ ។ ក្នុងនេះផងដែរ អ្នកក៏អាចស្នើសុំអ្នកផ្តល់សេវាថែទាំសុខភាព និងអ្នកផ្តល់សេវាដទៃទៀត របស់អ្នក ដែលអ្នកជ្រើសរើស នូវការប៉ាន់ប្រមាណថ្លៃថែទាំសុខភាពប្រកបដោយភាពជាក់លាក់ មុនពេលអ្នករៀបចំពេលទទួលឧបករណ៍/បរិក្ខារពេទ្យ ឬសេវាវេជ្ជសាស្ត្រ នោះ ។

» បើអ្នកទទួលបានប័ណ្ណបង់ប្រាក់ ដែលមានទឹកប្រាក់ យ៉ាងហោចណាស់ $400 ច្រើនជាងទឹកប្រាក់ ដែលមានក្នុងប័ណ្ណការប៉ាន់ប្រមាណថ្លៃថែទាំសុខភាពប្រកបដោយភាពជាក់លាក់ របស់អ្នក, អ្នកអាចតវ៉ារឿងនេះបាន ។

» សូមកុំភ្លេចរក្សាទុកសំណៅថតចម្លង ឬសំណៅរូបថត នូវប័ណ្ណការប៉ាន់ប្រមាណថ្លៃថែទាំសុខភាពប្រកបដោយភាពជាក់លាក់ របស់អ្នក ។

បើអ្នកមានសំណួរ ឬចង់ដឹងព័ត៌មានបន្ថែម អំពីសិទ្ធិរបស់អ្នក ចំពោះប័ណ្ណការប៉ាន់ប្រមាណថ្លៃថែទាំសុខភាពប្រកបដោយភាពជាក់លាក់ សូមចូលទៅកាន់ www.cms.gov/nosurprises ឬហៅទូរស័ព្ទមកលេខ (651) 968-5050 ។

SUMMIT
ORTHOPEDICS